# Living the Lotus 3

## Buddhism in Everyday Life

2024

VOL. 222




**Living the Lotus**
**Vol.222 (March 2024)**

Senior Editor: Keiichi Akagawa
Editor: Sachi Mikawa
Copy Editor: Penn Setharin
*Living the Lotus* is published monthly by Rissho Kosei-kai International, Fumon Media Center, 2-7-1 Wada, Suginami-ku, Tokyo 166-8537, Japan.
TEL: +81-3-5341-1124
FAX: +81-3-5341-1224
Email: living.the.lotus.rk-international@kosei-kai.or.jp

រីហ្សូកូសេកៃគឺជាអង្គការចលនាពុទ្ធសាសនាសកលមួយដែលមានពុទ្ធបរិស័ទ ជាច្រើនមានជំនឿលើគម្ពីព្រះសូត្រផ្កាឈូកសដែលជាព្រះសូត្ររបស់ព្រះពុទ្ធសាសនាមួយដ៏សំខាន់។ ពុទ្ធបរិស័ទទាំងនោះ បានខិតខំអនុវត្តការបង្រៀន របស់ព្រះបរមគ្រូនៃយើងទៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃដូចជា នៅកន្លែងការ ងារឬនៅក្នុងក្រុមគ្រួសាររបស់ពួកគាត់ជាដើម។ជាពិសេសគឺខំប្រឹងអនុវត្តធ្វើយ៉ាងណាអោយពិភពលោកទទួលបានសុខសន្តិភាព។

អង្គការរីហ្សូកូសេកៃ ត្រូវបានបង្កើតឡើងនៅឆ្នាំ 1983 ដោយ ស្ថាបនិក Nikkyo Niwano (1906-1999) និង, សហស្ថាបនាយិកា Myoko Naganuma (1889-1957) បច្ចុប្បន្នក្រោមការណែនាំពីលោកប្រធាន Nichiko Niwano សមាជិករីហ្សូកូ សេកៃទាំងអស់ក្នុងនាមជាពុទ្ធបរិស័ទបានកំពុងប្រឹងប្រែងយ៉ាងសកម្មក្នុងការចែករំលែកព្រះធម៌និងចូលរួមសកម្មភាពសន្តិភាពទាំងក្នុងនិងក្រៅប្រទេសក្នុងកិច្ចសហការជាមួយមនុស្សគ្រប់មជ្ឈដ្ឋាន។

The title of this newsletter, *Living the Lotus—Buddhism in Everyday Life*, conveys our hope of striving to practice the teachings of the Lotus Sutra in daily life in an imperfect world to enrich and make our lives more worthwhile, like beautiful lotus flowers blooming in a muddy pond. This newsletter aims to help people around the world apply Buddhism more easily in their daily lives.



# សេចក្ដីសម្រួម កើតមកពី មេត្តាករុណា

ព្រះគ្រូនីវ៉ាណុ នីជិកុ
ព្រះប្រធានរីហ្សូកូសេកៃ

## សេចក្ដីសម្រួមគឺសមានចិត្តចំពោះអ្នកដទៃ

“អាត្មារកបោសសំបុកពីងពាងដែលព័ទ្ធលើរុក្ខជាតិតែក៏ឈប់វិញភ្លាម” ។គឺជាកំណាព្យមួយវគ្គដែលពោរពេញទៅដោយសប្បុរសធម៌និងភាពកក់ក្ដៅរបស់ព្រះគ្រូរ្យោកាំងដែលជាព្រះសង្ឃនិកាយហ្សេង។យើងមើលឃើញដល់ទៅស្នាមញញឹមរបស់លោកនៅពេលដែលលោករកបោសសំបុកពីងពាងហើយស្រាប់តែប្រទះឃើញជីវិតដ៏តូចដែលខំរស់ លោកក៏ទុចដៃទាំងមិនដឹងខ្លួន។

នៅក្នុងកូនស្នាដៃដែលលោកខ្សៀកមួយខ្វាកនេះយើងទទួលអារម្មណ៍នូវភាពសម្រួមដ៏ជ្រាលជ្រៅនិងសេចក្ដីមេត្តាករុណាដែលឱបក្រសោបអ្វីៗទាំងអស់។

ពាក់ព័ន្ធនឹងការសម្រួមដ៏ជ្រាលជ្រៅ ដូចជាការស្គាល់ខ្មាសដែលខ្ញុំព្រះករុណាអាត្មាភាពបានលើកយកមកនិយាយនៅខែមុនដែរ ព្រះសម្មាសម្ពុទ្ធលោកឧស្សាហ៍មានពុទ្ធដីកាពីសារៈសំខាន់នៃ “ការសម្រួមកាយនិងវាចាឬពាក្យសម្ដី” ព្រមទាំងបន្ថែមទៀតថា “ការសម្រួមកាយ ពាក្យសម្ដីនិងចិត្តគឺជាទង្វើល្អប្រសើរ”។

យើងទាំងឡាយច្រើនតែចាត់ទុកព្រះពុទ្ធដីកានេះជាគម្រូសម្រាប់ជីវភាពរស់នៅជាទូទៅ ក៏ប៉ុន្តែដូចដែលបានឃើញយោលទៅតាមកំណាព្យរបស់ព្រះគ្រូរ្យោកាំងដែរខ្ញុំព្រះករុណាអាត្មាភាពយល់ថាការសម្រួមនិងមេត្តាករុណាគឺជារបស់ពីរដែលដូចគ្នា។ព្រះសង្ឃណាវ៉ាយ៉ាស៊ឺអាគីដែលជាព្រះសង្ឃនិកាយសូតូស្ហូបានមានសង្ឃដីកាថា ធម៌របស់ព្រះពុទ្ធទាំងអស់មានមូលដ្ឋានគ្រឹះជា“សេចក្ដីមេត្តាករុណា” ។ដូច្នេះដោយ សារតែការសម្រួមធ្វើឱ្យសមានចិត្តទៅលើអ្នកដទៃមានជម្រៅកាន់តែជ្រៅបែបនេះហើយ ទើបបានជាក្លាយទៅជាធម៌ព្រះពុទ្ធនោះ។

បើដូច្នេះតើយើងគ្រប់គ្នាអាចធ្វើឱ្យបានដូចព្រះគ្រូរ្យោកាំងដែរឬទេ ?ចំពោះសំណួរបែបនេះយើងដែលមិនទាន់បានប្រតិបត្តិដល់កម្រិតនៅឡើយនោះច្បាស់ជាមិនហ៊ានឆ្លើយទេ។បើដូច្នេះសុំត្រឹមតែថានៅពេលដែលចាប់ភ្លឹកគួរតែប្រយ័ត្នប្រយែងធ្វើយ៉ាងណាឱ្យពាក្យសម្ដីយើងមានភាពសម្រួមនិង ប្រកបទៅដោយសមានចិត្តចំពោះដៃគូ។

ហេតុអ្វីបានជានិយាយបែបនេះ ?បើមើលទៅសង្ឃដីការបស់ព្រះសង្ឃណាវ៉ា សេចក្ដីមេត្តា ករុណានឹងរីកកាន់តែធំហើយឡើងចាស់ទុំយោលទៅតាមការអនុវត្តន៍និងការហាត់ធ្វើជាប្រចាំ។មិនមែនលុះត្រាតែត្រាស់ដឹងទើបបានសេចក្ដីមេត្តាករុណាកើតមានឡើង ហើយទង្វើប្រកបទៅដោយសមានចិត្តដ៏ជ្រាលជ្រៅអាច

ប្រព្រឹត្តទៅបាននោះទេ សំខាន់គឺការចាប់ភ្លឹកទៅលើការនិយាយប្រកបទៅដោយសមានចិត្តនិងការសម្រួមចំពោះអ្នកដទៃនោះហើយដែលផ្ជាប់មនុស្សទាំងគេទាំងយើងឱ្យទៅជាជីវិតមួយហើយនៅចំណុចនោះការត្រាស់ដឹងមួយក៏កើតឡើង។

## ចាប់ផ្ដើមពីកិច្ចប្រតិបត្តិរៀងៗអាយឆ្ពោះទៅរកបញ្ហានៃពិភពលោក

និយាយអឺចឹងនៅឆ្នាំដែលចាប់កសាងព្រះវិហារនៅកន្លែងប្រតិបត្តិព្រះធម៌នៅណេម៉ូតូនៅថ្ងៃទី៤ខែមីនារបស់សមាគមយើងបើគិតពីឥឡូវនេះទៅរយៈពេល៦០ឆ្នាំបានកន្លងទៅហើយ កៃស្ទសាម៉ាលោកបានមានសង្ឃដីកាថា "សមាគមសាសនាមួយត្រូវបានបង្កើតឡើងនៅពេលដែលព្រះវិហារមួយកើតឡើង" ។ គឺព្រះអង្គចង់ប្រាប់យើងថាមានអាគារធំ មិនមែនមានន័យថា សមាគមសាសនាមានភាពចាស់ទុំនោះទេ ហើយការសាងសង់ព្រះវិហារក៏មិនមានន័យថា សមាគមសាសនាមានភាពចាស់ទុំដែរ ផ្ទុយទៅវិញ គឺជាសមាគមសាសនាដែលពុទ្ធបរិស័ទម្នាក់ៗមកប្រមូលផ្ដុំប្រជុំគ្នារៀនធម៌របស់ព្រះពុទ្ធ ដោយភាពសប្បាយរីករាយ សុភាពរាបសានិងសម្រួម ផ្ដល់ភាពកក់ក្ដៅ និងឋាមពលយ៉ាងជ្រាលជ្រៅទៅដល់បេះដូងរបស់មនុស្សក្នុងសហគមន៍ និងសង្គម។

ក្នុងន័យនេះយើងឃើញនូវសារសំខាន់ នៃការបន្តសកម្មភាព “ចលនាផ្ដល់អាហារមួយពេល” ដែលសមាគមយើងបានធ្វើជាយូរឆ្នាំមកហើយ។ចលនានេះត្រូវបានអនុវត្តដំបូងដោយសមាជិកនៃក្រុមយ៉ាម៉ាតូយ៉ាម៉ានៃស្ញូរ៉ុគឺស៊ីនតូ（Shoroku Shinto Yamatoyama）។ពួកគេបានប្រតិបត្តិបេះដូងនៃក្ដីមេត្តារបស់ពួកគេដោយឱ្យមនុស្សម្នាក់ៗបរិច្ចាគចំនួនទឹកប្រាក់ដែលពួកគេតមអាហារបីបួនដងក្នុងមួយខែមកសមា គមហើយសកម្មភាពនេះបង្កើតផលជាការរួមចំណែកដល់សង្គម។ យើងសង្ឃឹមថាពីនេះតទៅមុខក៏នឹងបន្តសកម្មភាពនេះដែរ។

លើសពីនេះទៀតការចូលរួមសន្ទនាក្នុងគោលបំណងដោះស្រាយបញ្ហាសកលលោកក្នុងសន្និសីទពិភពលោកនៃអ្នកសាសនាសម្រាប់សន្តិភាព ជាមួយមិត្តសាសនាដែលអាចជម្នះលើសាសនាព្រមទាំងនិកាយផ្សេងៗបាននោះ លុះត្រាតែបុគ្គលម្នាក់ៗដែលមករួមប្រជុំក្នុងកិច្ចប្រជុំមានភាពរាបសា អត់ធ្មត់ និង ភាពថ្លៃថ្នូរ ទើបអាចប្រព្រឹត្តទៅបាន។ យើងមានមោទនភាពចំពោះការកសាងជាគ្រឹះទុកឱ្យយើងទាំងអស់គ្នាដោយព្រះស្ថាបនិកកៃស្ទសាម៉ា ។ ក៏ប៉ុន្តែដើម្បីធានាឱ្យសកម្មភាពបែបនេះមិនឈប់ត្រឹមតែជានិមិត្តសញ្ញានោះ យើងត្រូវចងចាំជានិច្ចនូវភាពថ្លៃថ្នូរ និងប្រកាន់ខ្ជាប់នូវគោលការប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធគឺ មេត្តាករុណាហើយធ្វើសកម្មភាព។

ព្រះសម្មាសម្ពុទ្ធក៏បានមានពុទ្ធដីកាដែរថា “អ្នកដែលចេះសម្រួមនិងស្គាល់ខ្មាសនៅក្នុងកិច្ចការគ្រប់យ៉ាងអាចការពារខ្លួនឯងបាន” ។

នៅពេលដែលយើងទទួលយក "ខ្លួនឯង" នេះថាជា "ខ្លួនឯងដែលផ្ជាប់ទៅជាមួយទៅនឹងសកលលោកទាំងមូល" យើងនឹងកាន់ តែយល់ដឹងច្បាស់ពីសារៈសំខាន់នៃការ

សម្រួម កាយនិងពាក្យសម្ដី ហើយយើងគិតថាយើងម្នាក់ៗដែលរស់នៅគ្រប់ផ្នែកទាំងអស់នៃពិភពលោក គួរតែសម្រួមទាំងកាយវិការ និងការនិយាយស្ដីផងដែរ។



From *Kosei*, March 2024

# Rissho Kosei-kai International

## Make Every Encounter Matter




## A Global Buddhist Movement




**Information about local Dharma centers**

**facebook**

**twitter**

We welcome comments on our newsletter Living the Lotus: [living.the.lotus.rk-international@kosei-kai.or.jp](mailto:living.the.lotus.rk-international@kosei-kai.or.jp)